**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

លេខៈ ៩៤៧៦/១១២៥ ប.ស្ល/វហប

ថ្ងៃ អង្គារ ៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២៥

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក**

**នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**កម្មវត្ថុ** ៖ ករណីសំណើសុំធ្វើកិច្ចសន្យាការពារបរិស្ថាន សម្រាប់គម្រោងពង្រីកប្រព័ន្ធផលិតផ្គត់ផ្គង់ទឹកស្អាតនិរោធ ជំហានទី៣ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរាជធានីភ្នំពេញ។

**យោង** ៖ - ប្រកាសលេខ ៣៥៩១/០៥២៥ ប្រក ប.ស្ល/វហប ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥ របស់ក្រសួងបរិស្ថានស្តីពីចំណាត់ថ្នាក់គម្រោងអភិវឌ្ឍសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- លិខិតលេខ ៣២៤២ ឧវបន.ទស.លស ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- របាយការណ៍ចុះពិនិត្យទីតាំង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ របស់មន្ត្រីជំនាញនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា ក្រសួងបរិស្ថានឯកភាពលើកិច្ចសន្យាការពារបរិស្ថាន សម្រាប់គម្រោងពង្រីកប្រព័ន្ធផលិតផ្គត់ផ្គង់ទឹកស្អាតនិរោធ ជំហានទី៣ ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយឯកឧត្តមត្រូវគោរពតាមកិច្ចសន្យាការពារបរិស្ថានលេខ ១២០២ លស ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ចាត់ចែងតាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវសេចក្តីរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**អ៊ាង សុផល្លែត**

ចម្លងជូនៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- ឯកសារ កាលប្បវត្តិ

អគារមរតកតេជោ ដីឡូត៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 213 908 / 023 220 369

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខៈ ១២០២៣.ភ.

ថ្ងៃ.ពុធ.៧រោច.....ខែ.កត្តិក.........ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី..១២..ខែ..វិច្ឆិកា..ឆ្នាំ២០២៥

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ម្ចាស់គម្រោង) តំណាងដោយ **ឯកឧត្តម ឡុង ណារ៉ូ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** មានអាសយដ្ឋាន អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**សូមធ្វើកិច្ចសន្យាការពារបរិស្ថាន**

ដើម្បីរួមចំណែកជានានូវនិរន្តរភាពបរិស្ថានក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ម្ចាស់គម្រោង) សូមធ្វើកិច្ចសន្យាការពារបរិស្ថានចំពោះក្រសួងបរិស្ថាន សម្រាប់គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតនិរោធ ជំហានទី៣ ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ តាមប្រការដូចខាងក្រោមៈ

**ប្រការ១..**

ជានាទទួលខុសត្រូវ និងអនុវត្តនូវខ្លឹមសារ ដែលបានរៀបរាប់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន (EMP) សម្រាប់គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតនិរោធ ជំហានទី៣។

**ប្រការ២..**

ជានាផ្តល់របាយការណ៍អង្កេតតាមដានបរិស្ថាន (Environmental Monitoring Report) រៀងរាល់៦ខែម្តង នៅក្នុងកិច្ចដំណើរការគម្រោង ជូនក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងវាយតម្លៃ។

**ប្រការ៣..**

ជានាផ្តល់របាយការណ៍សង្ខេបនៃការសិក្សាលម្អិត (Summary Detailed Design Report) សម្រាប់គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតនិរោធ ជំហានទី៣ ដែលមិនបានលម្អិតនៅក្នុងរបាយការណ៍ EMP ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់។

**ប្រការ៤..**

ក្នុងករណីក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់គម្រោងធ្វើការកែប្រែនូវបច្ចេកទេសបរិស្ថានណាមួយ ដើម្បីឱ្យសមស្របទៅតាមគោលការណ៍ណែនាំ និងកម្រិតបទដ្ឋានបរិស្ថាន ម្ចាស់គម្រោងនឹងទទួលអនុវត្តទៅតាមគោលការណ៍ណែនាំនោះទាំងស្រុង។



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

**ប្រការ៥..**

ទៅថ្ងៃអនាគត បើម្ចាស់គម្រោងមានគម្រោងពង្រីកបន្ថែម ឬផ្លាស់ប្តូរ ឬកែសម្រួលរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព (Feasibility Study Report) ឬផ្អាកសកម្មភាព ម្ចាស់គម្រោងនឹងរាយការណ៍ជូនក្រសួងបរិស្ថានឱ្យបានមុន ១ខែ។

**ប្រការ៦..**

អនុញ្ញាតឱ្យមន្ត្រីជំនាញពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានីភ្នំពេញ ដែលមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ដើម្បីធ្វើការត្រួតពិនិត្យនៅតំបន់គម្រោងអភិវឌ្ឍន៍។

**ប្រការ៧..**

ត្រូវធ្វើយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកដល់កម្មករនៅក្នុងតំបន់គម្រោងជាប្រចាំ រហូតដល់ឈប់មានការប្រើប្រាស់ថង់ប្លាស្ទិក។

**ប្រការ៨..**

ម្ចាស់គម្រោងត្រូវគោរពតាមច្បាប់ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាលកម្ពុជាជាធរមាន។

**ប្រការ៩..**

កិច្ចសន្យាការពារបរិស្ថាននេះត្រូវតម្កល់ទុកនៅខុទ្ទកាល័យ**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**ចំនួន ១(មួយ)ច្បាប់ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំនួន ១(មួយ)ច្បាប់ ការិយាល័យមេធាវីក្រសួងបរិស្ថានចំនួន ១(មួយ)ច្បាប់ និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញចំនួន ១(មួយ)ច្បាប់ ដើម្បីទុកជាសក្ខីភាពចំពោះមុខច្បាប់ជាធរមាន។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**ឡុង ណារ៉ូ**

បានឃើញ និងសូមគោរពជូន
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** មេត្តាពិនិត្យ និងសម្រេច
លេខៈ ១៥១៥ វ.ហ.ប.ស្ថ
ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០២៥
**ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

**ជួប ស៊ីវុត្ថា**

បានឃើញ និងឯកភាព
ថ្ងៃអង្គារ ៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២៥
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**អ៊ាង សុផល្លែត**